UNITED NATIONS NATIONS UNIES

# លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ

~~~

# សារលិខិតថ្លែងស្តីពីទិវាសិទ្ធិមនុស្ស

ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៧

នៅក្នុងឱកាសទិវាសិទ្ធិមនុស្សឆ្នាំនេះ យើងទាំងអស់គ្នាប្រកាសបើកពិធីរំលឹកខួបរយៈពេលមួយឆ្នាំនៃខួបលើកទី៦០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ។ គ្រួសារទាំងអស់នៃអង្គការសហប្រជាជាតិ នឹងចូលរួមក្នុងយុទ្ធនា-ការមួយ ដើម្បីលើកកំពស់ឧត្តមគតិនៃសេចក្តីប្រកាសនេះ និងគោលការណ៍នានា ស្តីពីយុត្តិធម៌ និងសមភាពសំរាប់មនុស្សគ្រប់រូប ។

យុទ្ធនាការនេះ រំលឹកប្រាប់យើងទាំងអស់គ្នាថា ពិភពលោកនៅតែជាប់ជិតដាមដោយភាពភ័យរន្ធត់ពីសង្គ្រាមលោកលើកទីពីរនៅឡើយ សេចក្តីប្រកាសនេះ គឺជាសេចក្តីថ្លែងការណ៍ជាសកលដំបូងគេបង្អស់ នៃអ្វីដែលយើងសន្មត់នៅពេលនេះ គឺសេចក្តីថ្លៃថ្នូរ និងសមភាពដែលមានតាំងពីកំណើតរបស់មនុស្សគ្រប់រូប ។

ចក្ខុវិស័យដ៏អស្ចារ្យនេះ និងការប្តេជ្ញាចិត្តរបស់អ្នកតាក់តែង បានបង្កើតជាឯកសារមួយដែលដំបូងបង្អស់ បានកំណត់អំពីសិទ្ធិមនុស្សជាសកលសំរាប់មនុស្សគ្រប់រូប ស្ថិតក្នុងបរិបទដោយឡែកពីគ្នា។ បច្ចុប្បន្ននេះ អត្ថបទនេះមានច្រើនជាង ៣៦០ ភាសា សេចក្តីប្រកាសនេះ គឺជាឯកសារមួយដែលត្រូវបានបកប្រែច្រើនជាងគេបង្អស់លើពិភពលោក — ជាឯកសារយថាភូត ដែលមានចរិតលក្ខណៈ និងវិសាលភាពជាសកល ។ សេចក្តីប្រកាសជាសកលនេះ ត្រូវបានចារិកនៅក្នុងរដ្ឋធម្មនុញ្ញនៃរដ្ឋទាំងឡាយដែលទើបទទួលបានឯករាជ្យ និងរដ្ឋជាច្រើនដែលទើបប្រកាន់លិទ្ធិប្រជាធិបតេយ្យ ។ ឯកសារនេះ បានក្លាយជារង្វាស់មួយ ដែលតាមរយៈនេះ យើងអាចធ្វើការវាស់ស្ទង់អំពីការគោរពនូវអ្វីដែលយើងដឹង ឬគួរដឹងថា ត្រូវ និងខុស ។
~~~

សេចក្តីប្រកាសនេះ ស្ថិតនៅជាធរមានរហូតដល់ពេលបច្ចុប្បន្ននេះ ដូចមាននៅថ្ងៃដែលវាត្រូវបានអនុម័ត ។ ប៉ុន្តែ សេរីភាពជាមូលដ្ឋាន ដែលបានតំកល់ក្នុងសេចក្តីប្រកាសនេះ នៅមិនទាន់ស្តែងចេញជាការពិតសំរាប់មនុស្សគ្រប់រូបនៅឡើយទេ ។ ជាញឹកញយបំផុត រដ្ឋាភិបាលនានា ខ្វះឆន្ទះនយោបាយក្នុងការអនុវត្តន៏បទដ្ឋានអន្តរជាតិ ដែលខ្លួនបានទទួលយកដោយស្ម័គ្រចិត្ត ។

ទិវារំលឹកខួបឆ្នាំនេះ គឺជាឱកាសមួយ ដើម្បីពង្រឹកឆន្ទះនោះ ។ វាគឺជាឱកាសមួយ ដើម្បីបញ្ជាក់ថា សិទ្ធិទាំងនេះមានប្រាកដមែន -- ហើយថាមនុស្សគ្រប់រូបបានដឹង បានយល់ និងបានទទួលសិទ្ធិទាំងនេះ នៅគ្រប់ទីកន្លែងទាំងអស់ ។ ជារឿយៗ ជនទាំងឡាយដែលត្រូវការឱ្យមានការការពារសិទ្ធិរបស់ខ្លួន ក៏ត្រូវតែបានប្រាប់ឱ្យដឹងថា មានសេចក្តីប្រកាសនេះ — ហើយថា សេចក្តីប្រកាសនេះ ធ្វើឡើងសំរាប់ពួកគេ ។

សូមឱ្យទិវារំលឹកខួបឆ្នាំនេះ ផ្តល់ជាកម្លាំងឱ្យយើងទាំងអស់គ្នា ក្នុងការបំពេញបេសកម្មនោះ ។ ចូរយើងទាំងអស់គ្នា ប្រែក្លាយសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស ទៅជាផ្នែកទាំងមូលនៃជីវិតមនុស្សគ្រប់រូប ។

End.